ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

លេខ : ០៧២ សំណ ន / គ.ឃ.ស

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០៣

# សេចក្តីណែនាំ

## ស្តីពីការសុំច្បាប់ឈប់សម្រាករបស់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

យោងតាម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកាសលេខ ១៨៨៤ ប្រក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ០០៤ សជណ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្នុងគោលបំណងដើម្បីលើកកំពស់ប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់សូមធ្វើការណែនាំអំពីរបៀបរបបសំរាប់ការសុំអនុញ្ញាតច្បាប់ឈប់សំរាកពីការងាររបស់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានដូចខាងក្រោម :

១. អំពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ :

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មិនមែនជាមន្ត្រីនៃក្របខ័ណ្ឌមុខងារសាធារណៈឡើយ មន្ត្រីទាំងនេះត្រូវបានជ្រើសរើសចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក្នុងតាមការបោះឆ្នោតមូលដ្ឋាន ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលពុំមានតួនាទីជាមេឃុំ ចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង មិនតម្រូវឱ្យមកបំពេញការងារប្រចាំថ្ងៃនៅសាលាឃុំ សង្កាត់ទេ លើកលែងតែមានការប្រគល់ការងារពីមេឃុំ ចៅសង្កាត់ ឬក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានធុរៈផ្ទាល់ខ្លួន ឬមានភារកិច្ចតម្រូវដោយគណបក្សនយោបាយរបស់ខ្លួន ឬមានជម្ងឺ ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ឬក្នុងពេលដែលសមាជិកនោះត្រូវបានចាត់ឱ្យបំពេញការងារណាមួយ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ឬដោយមេឃុំ ចៅសង្កាត់ សមាជិករូបនោះត្រូវធ្វើពាក្យសុំអនុញ្ញាតច្បាប់ពីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ស្របតាមនីតិវិធីដូចមានចែងក្នុងជំពូក ៧ នៃគំរូបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានភ្ជាប់ជាមួយនឹងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ០០៤ សជណ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ អាចអនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សាអវត្តមានក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបានតែមួយលើកប៉ុណ្ណោះ (តាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំយ៉ាងតិចម្តងក្នុងមួយខែ) ។ ក្នុងករណីសមាជិកក្រុមប្រឹក្សាមិនអាចមកចូលរួមប្រជុំក្រុមប្រឹក្សាពីរលើកជាប់ៗគ្នា ពាក្យសុំឈប់សំរាកនោះត្រូវដាក់សុំការសំរេចពីក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្នុងករណីសមាជិកក្រុមប្រឹក្សាមានជម្ងឺមិនអាចមកចូលរួមប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់លើសពីពីរលើកឡើងទៅ ត្រូវមានលិខិតបញ្ជាក់ពីគ្រូពេទ្យ ។

២. <u>ករណីមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង</u> :

ចំពោះសមាជិកក្រុមប្រឹក្សាឃុំ ឃុំសង្កាត់ ដែលទទួលតំណែងជាមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង គឺជាអ្នកទទួលអំណាចចាត់ចែងកិច្ចការប្រចាំថ្ងៃនៅឃុំ សង្កាត់ ។ តាមមាត្រា ៧ នៃអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមិនា ឆ្នាំ ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ បានកំណត់ឱ្យសាលាឃុំ សង្កាត់ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការប្រចាំថ្ងៃ ដូចក្រសួងស្ថាប័នទាន់របស់រាជរដ្ឋាភិបាលដែរ ។ ហេតុនេះ ក្នុងពេលម៉ោងធ្វើការប្រចាំថ្ងៃ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ត្រូវមានវត្តមាននៅសាលាឃុំ សង្កាត់របស់ខ្លួនឱ្យបានជាប្រចាំ ។ ក្នុងករណីមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មានកិច្ចការចាំបាច់ដែលតម្រូវដោយគណបក្សនយោបាយរបស់ខ្លួន ឬមានធុរៈផ្ទាល់ខ្លួន ឬមានជម្ងឺមិនអាចមកបំពេញភារកិច្ចបាន ត្រូវសុំអនុញ្ញាតច្បាប់ឈប់សំរាកពីការងារតាមនីតិវិធីដូចខាងក្រោម :

-ចំពោះមេឃុំ ចៅសង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់សំរាកពីការងារមកអភិបាលខេត្ត ក្រុងសាមី ។ អភិបាលខេត្ត ក្រុងអាចអនុញ្ញាតច្បាប់ឈប់សំរាកការងារជូនមេឃុំ ចៅសង្កាត់យ៉ាងច្រើនត្រឹមរយៈពេល ៣០ ថ្ងៃប៉ុណ្ណោះ ។ ប្រសិនបើមេឃុំ ចៅសង្កាត់សុំច្បាប់ឈប់

សំរាកពីការងារលើសពី ៣០ថ្ងៃ មេឃុំ ចៅសង្កាត់ត្រូវដាក់ពាក្យសុំអនុញ្ញាតច្បាប់នោះជូនក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីពិភាក្សា និងអនុម័ត ហើយដាក់ជូនអភិបាលខេត្ត ក្រុងសាមី ដើម្បីលើកយោបល់ជូនមកក្រសួងមហាផ្ទៃ ។ ក្នុងពេលអវត្តមាន មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រងតាមឋានានុក្រម ត្រូវទទួលភារកិច្ចជំនួសស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

-ចំពោះជំទប់ និងចៅសង្កាត់រងដែលមានធុរៈផ្ទាល់ខ្លួន ឬមានភារកិច្ចតម្រូវដោយគណបក្សនយោបាយរបស់ខ្លួន ឬមានជម្ងឺ ត្រូវដាក់ពាក្យសុំច្បាប់ឈប់សំរាកពីការងារទៅមេឃុំ ចៅសង្កាត់ ។ មេឃុំ ចៅសង្កាត់ អាចអនុញ្ញាតច្បាប់សំរាកជូនជំទប់ ចៅសង្កាត់រងបានយ៉ាងច្រើនត្រឹម ៣០ ថ្ងៃប៉ុណ្ណោះ ក្នុងករណីលើសពីនេះ ពាក្យសុំឈប់សំរាករបស់ជំទប់ ចៅសង្កាត់រង ត្រូវបញ្ជូនទៅសុំការសំរេចពីក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន រួចហើយមេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាលខេត្ត ក្រុងសាមី ។

ទទួលបានសេចក្តីណែនាំនេះ អភិបាលខេត្ត ក្រុង ត្រូវផ្សព្វផ្សាយដល់គ្រប់ឃុំ សង្កាត់ ណែនាំ និងពិនិត្យតាមដាន ក្នុងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ។

ជ. គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
សមាជិកអចិន្ត្រៃយ៍

<u>ចម្លងជូន</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល
"ដើម្បីជូនជ្រាប"
-អគ្គលេខាធិការដ្ឋាននៃក្រសួងមហាផ្ទៃ
-អគ្គស្នងការដ្ឋាននគរបាលជាតិ
-អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ
-អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាលនិងនគរបាល
-គ្រប់សាលាខេត្ត ក្រុង
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ